ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
លេខ: ០៤៣៨ វ.ប.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសនិស្សិតចូលរៀនកម្រិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្ម នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

### I- ចំនួនជ្រើសរើស

ក្នុងឆ្នាំសិក្សា ២០២២-២០២៣នេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក) នឹងជ្រើសរើសនិស្សិតឱ្យចូលរៀន នៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្ម ចំនួន ២១០ នាក់ដែលត្រូវបែងចែកតាមជំនាញឯកទេសដូចខាងក្រោម ៖

| | |
|---|---|
| ១. វិស្វកម្មរូបធាតុ និងគ្រឿងផ្គុំ (សញ្ញាបត្រពីរជាមួយ INSA de Rennes ប្រទេសបារាំង) | ចំនួន ៣០ នាក់ |
| ២. វិស្វកម្មទឹក និងបរិស្ថាន | ចំនួន ៣០ នាក់ |
| ៣. វិស្វកម្មកសិឧស្សាហកម្ម | ចំនួន ៣០ នាក់ |
| ៤. វិទ្យាសាស្ត្រកុំព្យូទ័រ | ចំនួន ៣០ នាក់ |
| ៥. វិស្វកម្មមេកាត្រូនិច ព័ត៌មាន និងគមនាគមន៍ | ចំនួន ៣០ នាក់ |
| ៦. វិស្វកម្មបច្ចេកវិទ្យា និងការគ្រប់គ្រងថាមពល | ចំនួន ៣០ នាក់ |
| ៧. វិស្វកម្មដឹកជញ្ជូន | ចំនួន ៣០ នាក់ |

### II- រចនាសម្ព័ន្ធសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្មនេះមានរយៈពេលពីរឆ្នាំ (M1 និង M2) និងមានក្រេឌីត សិក្សាក្នុងរង្វង់ ៥០-៥៤ ក្រេឌីត ចែកចេញជាពីរច្រកសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាលើមុខវិជ្ជា និងស្រាវជ្រាវ (Course and Research pathway) និងបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការស្រាវជ្រាវ (Research-based pathway) ។ យោងតាមប្រកាសលេខ២៩៧៩ អយក.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួង អប់រំ យុវជន និងកីឡា និស្សិតដែលមានសញ្ញាបត្រវិស្វករពី វ.ប.ក អាចសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្ម នេះក្នុងរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ (M2)។ ការសម្រេចឱ្យនិស្សិតណាម្នាក់ទទួលបានការផ្ទេរក្រេឌីត ឬកម្មវិធី ឆ្លងឆ្នាំនេះនឹងត្រូវធ្វើឡើងដោយគណៈកម្មការជ្រើសរើសមួយ។ សម្រាប់ព័ត៌មានលម្អិតអំពីកម្មវិធីសិក្សាសូម ចូលទៅកាន់តំណភ្ជាប់ https://bit.ly/itcmaster2022-23 ។

### III- លក្ខខណ្ឌនៃការជ្រើសរើស

បេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យចូលរៀនត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃសមមូល

២. មានសញ្ញាបត្រវិស្វករ បរិញ្ញាបត្រវិទ្យាសាស្ត្រ ឬសញ្ញាបត្រដែលមានតម្លៃសមមូល

៣. មានចំណេះដឹងភាសាអង់គ្លេស ឬភាសាបារាំងក្នុងកម្រិតអាចប្រើប្រាស់បាន



មហាវិថី សហពន្ធ័រុស្ស៊ី ប្រអប់សំបុត្រលេខ ៨៦ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា – www.itc.edu.kh
ទូរស័ព្ទ : (855) 23 880 370 ទូរសារ : (855) 23 880 369 E-mail : info@itc.edu.kh

## IV- សំណុំលិខិតនៃការដាក់ពាក្យសុំ

បេក្ខជនត្រូវបំពេញពាក្យសុំចូលរៀន និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១. សំណើពាក្យសុំ (មានគំរូ) ........................................ ១ ច្បាប់
២. ប្រវត្តិរូបសង្ខេបមានបិទរូបថត ........................................ ១ ច្បាប់
៣. រូបថតថ្មីទំហំ ៤x៦ ........................................ ៦ សន្លឹក
៤. សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃសមមូល ........................................ ១ ច្បាប់
៥. ព្រឹត្តិបត្រពិន្ទុពីឆ្នាំទីមួយដល់ឆ្នាំបញ្ចប់ ........................................ ១ ច្បាប់
៦. លិខិតបញ្ជាក់ពីកម្រិតចំណេះដឹងភាសាអង់គ្លេស ឬភាសាបារាំង ........................................ ១ ច្បាប់
៧. លិខិតផ្ដល់យោបល់បិទជិតពីសាស្ត្រាចារ្យ ........................................ ១ ច្បាប់
៨. លិខិតផ្ដល់យោបល់បិទជិតពីអ្នកទទួលខុសត្រូវ (បើមាន) ........................................ ១ ច្បាប់
៩. លិខិតបញ្ជាក់ពីសក្ដានុពលនិងគោលបំណង (Motivation letter) ........................................ ១ ច្បាប់

## V- កាលបរិច្ឆេទទទួលពាក្យ និងកន្លែងទទួលពាក្យ

បេក្ខជនអាចយកគំរូពាក្យសុំនៅសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក ៖ បន្ទប់លេខ១១០ អគារ B មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ឬអាចទាញយកគំរូពាក្យសុំនេះជាទម្រង់ PDF តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់សាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក www.facebook.com/itcgraduate ឬ Telegram Channel https://t.me/s/itc_graduate_school ។ បេក្ខជនអាចមកយក និងដាក់ ពាក្យសុំចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១១:០០ ព្រឹកនៅសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក។ បេក្ខជនត្រូវផ្ញើសំណុំឯកសារពាក្យសុំជាពីរទម្រង់គឺ Hard Copy និង PDF (សូមផ្ញើមកកាន់ Email: graduate@itc.edu.kh) ឱ្យបានមុនថ្ងៃផុតកំណត់។

## VI- ការជ្រើសរើស

ការជ្រើសរើសនិស្សិតឲ្យចូលសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្មនេះ ត្រូវធ្វើឡើងតាមរយៈការពិនិត្យនិងវាយតម្លៃលើសំណុំឯកសាររបស់បេក្ខជន ដោយគណៈកម្មការមួយដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីចាំបាច់ បេក្ខជនត្រូវឆ្លងកាត់ការធ្វើតេស្តវាស់សមត្ថភាពលើវិញ្ញាសាមួយចំនួនដែលតម្រូវដោយកម្មវិធីបណ្ដុះបណ្ដាល និងរៀបចំដោយគណៈកម្មការជ្រើសរើស។

## VII- ការប្រកាសលទ្ធផល

ការប្រកាសលទ្ធផលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ នៅ វ.ប.ក។

## VIII- ការចុះឈ្មោះចូលរៀន

ការចុះឈ្មោះចូលរៀននឹងប្រព្រឹត្តទៅចាប់ពីថ្ងៃប្រកាសលទ្ធផល។

## IX- បវេសនកាល

កាលបរិច្ឆេទនៃបវេសនកាលនឹងជូនដំណឹងនៅពេលក្រោយ។

## X- តម្លៃសិក្សា

និស្សិតបរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្មគ្រប់មុខជំនាញត្រូវបង់ថ្លៃសិក្សា ១២០០ (មួយពាន់ពីររយ) ដុល្លារសហរដ្ឋអាមេរិចសម្រាប់ការបង់មួយឆ្នាំសិក្សានិង ៦៥០ (ប្រាំមួយរយហាសិប) ដុល្លារសហរដ្ឋអាមេរិចសម្រាប់ការបង់មួយឆមាស។

__បញ្ជាក់__ ៖ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក. បន្ទប់លេខ ១១០ អគារ B ឬតាមរយៈ E-mail: graduate@itc.edu.kh ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២
**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

**បណ្ឌិត ប៉ូ គីមថូ**

__ចម្លងជូន ៖__

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ « __ដើម្បីជ្រាបជាព័ត៌មាន__ »
- ការិយាល័យសិក្សា
- គ្រប់ដេប៉ាតឺម៉ង់របស់ វ.ប.ក
- ផ្នែកផ្សព្វផ្សាយព័ត៌មាន « __ដើម្បីផ្សព្វផ្សាយ__ »
- កាលប្បវត្តិ
- ឯកសារ របក